**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ១០.អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែប្រែតំបន់ការពារធម្មជាតិពីឧទ្យានជាតិព្រះសីហនុ«រាម» ទៅជា ឧទ្យានជាតិសមុទ្រព្រះសីហនុរាម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការទទួលខុសត្រូវលើតំបន់ការពារធម្មជាតិ

- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

### មាត្រា១ .-

ត្រូវបានកែប្រែតំបន់ការពារធម្មជាតិពីឧទ្យានជាតិព្រះសីហនុ«រាម» ទៅជា ឧទ្យានជាតិសមុទ្រព្រះសីហនុរាម ដែលមានផ្ទៃសរុបទំហំ ៣៩ ៦៣៤(សាមសិបប្រាំបួនពាន់ប្រាំមួយរយសាមសិបបួន)ហិកតា តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 ស្ថិតក្នុងភូមិសាស្ត្រខេត្តព្រះសីហនុនិងខេត្តកំពត ដោយក្នុងនោះមានផ្ទៃដីទំហំ១៩ ៣៤០(ដប់ប្រាំបួនពាន់បីរយសែសិប)ហិកតា និងផ្ទៃទឹកទំហំ២០ ២៩៤(ម្ភៃពាន់ពីររយកៅសិបបួន)ហិកតា ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ១និងនិយាមកាភ្ជាប់ក្នុងឧបសម្ព័ន្ធ២នៃអនុក្រឹត្យនេះ។

### មាត្រា២ .-

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ៖

- លើកកម្ពស់តួនាទី សក្តានុពល និងកិត្យានុភាពនៃប្រព័ន្ធអេកូឡូស៊ីសមុទ្ររាមឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍន៍ដោយចីរភាព
- ថែរក្សាការពារមុខងារប្រព័ន្ធអេកូឡូស៊ីនៃឧទ្យានជាតិសមុទ្រព្រះសីហនុរាមឱ្យមាននិរន្តរភាព
- ជំរុញនិងលើកកម្ពស់ការការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងសហគមន៍មូលដ្ឋាន ដើម្បីរួមចំណែកក្នុងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការការពារធនធានធម្មជាតិ និងការរស់នៅដោយចីរភាព។

### មាត្រា៣ .-

ក្រសួងបរិស្ថានមានសមត្ថកិច្ចរៀបចំ កែប្រែ និងគ្រប់គ្រង តំបន់ឧទ្យានជាតិសមុទ្រព្រះសីហនុរាម ដោយសហការជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលខេត្តព្រះសីហនុនិងខេត្តកំពត ដើម្បីធានាដល់ប្រសិទ្ធភាពការងារគ្រប់គ្រងបរិស្ថាន និងការរស់នៅដោយចីរភាព ស្របតាមបទប្បញ្ញត្តិនៃច្បាប់ជាធរមាន។

### មាត្រា៤ .-

លិខិតបទដ្ឋានគតិយុត្តិដែលពាក់ព័ន្ធនឹងការកំណត់តំបន់សហគមន៍ តំបន់ប្រើប្រាស់ដោយចីរភាព ការធ្វើអនុបយោគ ការចេញប័ណ្ណដីធ្លី ឬការអនុញ្ញាតឱ្យប្រើប្រាស់ដីធ្លី ដែលប្រើឈ្មោះឧទ្យានជាតិព្រះសីហនុ«រាម» ត្រូវមានអនុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តិថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

### មាត្រា៥ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុនិងខេត្តកំពត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៨ កើត ខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**អន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ


ឧបសម្ព័ន្ធ១នៃអនុក្រឹត្យលេខ......១០........អនក្រ.បក ចុះថ្ងៃទី....១១......ខែ..មករា......ឆ្នាំ២០២២
ផែនទីឧទ្យានជាតិសមុទ្រព្រះសីហនុរាម ភូមិសាស្ត្រខេត្តព្រះសីហនុនិងខេត្តកំពត
៣៩ ៦៣៤ហិកតា
ផែនទី ព្រះរាជាណាចក្រកម្ពុជា
ប្រទេសថៃ
ប្រទេសឡាវ
ប្រទេសវៀតណាម
សញ្ញាណសម្គាល់
ផ្លូវទឹកផ្លូវជាតិ
សមុទ្រ
ព្រំប្រទល់ឧទ្យានជាតិសមុទ្រ
ព្រះសីហនុរាម(៣៩ ៦៣៤ហិកតា)
ឧទ្យានជាតិសមុទ្រព្រះសីហនុរាមមានផ្ទៃ
សរុបទំហំ ៣៩ ៦៣៤ហិកតា
ជ
ក
ត
ល
0 1 2 3 4 គីឡូម៉ែត្រ
MAP COORDINATION SYSTEM
Unit Meter System Projection: UTM, Zone 48
Horizontal Datum: WGS 1984